**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការកំពូល**
សភា រដ្ឋប្បវេណី
សំណុំរឿងរដ្ឋប្បវេណី
លេខៈ ០៥
ចុះថ្ងៃទី ០៨.០១.៩៨
**សាលដីកា**
លេខៈ ២០៤
ចុះថ្ងៃទី០២.១២.១៩៩៩

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការកំពូល**
បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី៣០.១១.៩៩ ដោយមានសមាសភាពដូចតទៅៈ
១- ឯកឧត្តម ........... ជាប្រធាន
២-លោក ................ ជាចៅក្រម
៣- លោក ............... ជាចៅក្រម
៤- លោក .............. ជាចៅក្រមរបាយការណ៍
៤-លោក ................ ជាចៅក្រម

**ក្រឡាបញ្ជី**
លោក.............................

**តំណាងមហាអយ្យការ**
លោក .................. ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីការដ្ឋប្បវេណីលេខ ៧០១ ចុះថ្ងៃទី ២៤.១១.៩៧ នៃសំណុំរឿងរដ្ឋប្បវេណីលេខ ៣៦៥ ចុះថ្ងៃទី ២៦.៦.៩៧ របស់សាលាឧទ្ធរណ៍ ។

រវាងម្ចាស់បណ្តឹងសាទុក្ខឈ្មោះ ឈនភេទ ស្រីអាយុ ៤១ ឆ្នាំ ជាតិខ្មែរ មុខរបរ នៅផ្ទះមានទីលំនៅភូមិទី២ ឃុំខ្សាម ស្រុកកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំ ។ ឪពុកឈ្មោះ ប្រាំង គន់ ម្តាយឈ្មោះ ឈឺន អ៊ុត ប្តីឈ្មោះ ហ៊ីង ណាត់ ។

នឹងចុងចម្លើយបណ្តឹងសាទុក្ខឈ្មោះ អម ភេទ ស្រី អាយុ ៣៨ ឆ្នាំ ជាតិខ្មែរ មុខរបរលក់ដូរមានទីលំនៅភូមិទី ២ ឃុំខ្សាម ស្រុកកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំ ។ឪពុកឈ្មោះ អ៊ុំ អឿន "ស"ម្តាយឈ្មោះ ប៉ែន ឈិ"ស" ប្តីឈ្មោះ ញ៉ោក ប៊ុន្នី។

កម្មវត្ថុបណ្តឹង ៖ ប្តឹងទារប្រាក់ជំពាក់ចំនួន ៩៦ ជី

តាមបណ្តឹងសាទុក្ខលេខ ៤៤៨ចុះថ្ងៃទី ២៤.១១.៩៧ របស់ឈ្មោះ ឈិន នីបានប្តឹងមិនសុខចិត្តនិងសេចក្តីសំរេចនៃសាលដីកាលេខ ៧០១ ចុះថ្ងៃទី២៤.១១.៩៧របស់សាលាឧទ្ធរណ៍លើចំណុចនៃសាលដីកាទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ០៥ ចុះថ្ងៃទី ០៨.០១.៩៨ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី ២៧.០៣.៩៦ របស់ដើមចោទឈ្មោះ ឈីន នី ប្តឹងពីឈ្មោះ អម និង ប្តីដោយសំអាងហេតុថាអ្នកគទាំងបីរបានមកដល់ផ្ទះខ្លួនខ្ចីប្រាក់ចងការចំនួន ពីរលើក គឺលើកទី ១ ចំនួន ២ ដំឡឹងមាស និងលើកទីពីរចំនួន ៨ ជី ដោយសុខចិត្តអោយការប្រាក់ ០៧ហ៊ុន ក្នុងមួយតំឡឹងមាស ហើយឈ្មោះ អម បានទុកប្លង់ដីភូមិ និង ផ្ទះ សំរាប់ជាភស្តុតាង នៅថ្ងៃទី ២៣.០៤.៩៣ ឈ្មោះ អម បានអោយការប្រាក់ខ្លួនចំនួន ២.០០០បាត និងនៅថ្ងៃ

ទី ២៦.០៩.៩៣ បានអោយបន្ថែមទៀតចំនួន ២១០ដុល្លា សរុបជាមាសចំនួន ០៧ជី ហើយរហូតមកដល់សព្វថ្ងៃ ឈ្មោះនេះមិនព្រមសងការប្រាក់ និង ប្រាក់ដើមអោយខ្លួនទេ ។

បានឃើញសាលក្រមលេខ ០៥ ចុះថ្ងៃទី ១០.០១.៩៧ របស់តុលាការខេត្តកំពង់ឆ្នាំង ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ ៖

១- ទទួលពាក្យបណ្តឹងរបស់ដើមចោទ ចុះថ្ងៃទី ២៧ ខែ ០៦ ឆ្នាំ ១៩៩៦ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២-អោយនាង អម "ចុងចម្លើយ"សងមាសទាំងដើមទាំងការសរុបចំនួន ៣៣ជី ៦ហ៊ុន មាសល្អ ទៅអោយនាង ឈីន នី "ដើមចោទ" វិញ ចាប់ពីថ្ងៃប្រកាសសាលក្រមស្ថាពរ ។

- បើរកមាសសងមិនបានត្រូវរឹបអូសយកដីភូមិនិងផ្ទះលក់ឡាយឡុង ។
- បើរឹបអូសយកដីភូមិ ផ្ទះលក់ឡាយឡុងមិនបានត្រូវដាក់គុកបង្ខំដល់រូបកាយចំនួន ៦ ខែ ។

៣-អោយនាង អឿន "ចុងចម្លើយ" បង់ប្រាក់ប្រដាប់ក្តី គឺពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹង ១.៨០០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហឹបប្រាក់២០០រៀល រង្វាន់អ្នកប្រគល់ដីកាកោះ ៥.០០០រៀល បូករួម ៧.០០០រៀលប្រាក់នេះបានកាត់យកពីប្រាក់ ៧.០០០រៀល នេះទៅដើមចោទវិញ និង បងពន្ធសមាមាត្រ ៤.២០០.០០គុណ១ / ១០០ = ៤២.០០០រៀល បន្ថែមទៀត ពន្ធសមាមាត្រ ៤២.០០០គុណ៨០ / ១០០ = ៨.៤០០រៀល ។

ពន្ធសមាមាត្រនេះត្រូវអោយដើមចោទបង់ទុកជាមុនដែរ រួចទើបអោយចុងចម្លើយបង់ជាក្រោយ ។

- តាមមាត្រា ៣-៤ នៃក្រឹត្យ-ច្បាប់លេខ ៣៨ ក្រ.ច. ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ១៩៨៨ ស្តីពីកិច្ចសន្យា និង ការទទួលខុសត្រូវក្រៅកិច្ចសន្យា ។
- តាមមាត្រា ១១៣ នៃច្បាប់ស្តីពីនីតិវិធីអនុវត្តសាលក្រមរដ្ឋប្បវេណី ។

សាលក្រមនេះជំនំជំរះជាសាធារណៈ នៅចំពោះមុខគូក្តី បើគូក្តីណាមួយមិនសុខចិត្តមានសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងរយះពេល ២ ខែ តាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ ... ចុះថ្ងៃទី ១៩.០២.៩៧ របស់ឈ្មោះ អម ប្តឹងមិនសុខចិត្តនិង សេចក្តីសំរេចនៃសាលក្រមលេខ ០៥ ចុះថ្ងៃទី ១០.០១.៩៧របស់តុលាការខេត្តកំពង់ឆ្នាំង ត្រង់ចំនុចនៃសាលក្រមទាំងមូល ។

បានឃើញសាលដីការលេខ ៧០១ ចុះថ្ងៃទី ២៤.១១.៩៧ របស់សាលាឧទ្ធរណ៍ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ ៖

១- ទទួលពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ១៩.០២.៩៧ របស់ឈ្មោះ អម ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២- បដិសេធសាលក្រមរដ្ឋប្បវេណីលេខ ០៥ចុះថ្ងៃទី ១០.០១.៩៧របស់តុលាការខេត្តកំពង់ឆ្នាំងចោលជាអសារបង់ ។

៣- បង្គាប់អោយឈ្មោះ ឈន ប្រគល់ប័ណ្ណសំគាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ គេ៤-០៣៨៧ ចុះថ្ងៃទី ១៨.៥.៩២អោយទៅឈ្មោះ អម វិញ ចាប់ពីថ្ងៃដែលសាលដីកានេះចូលជាស្ថាពរ ។

៤- កាត់យកប្រាក់ប្រដាប់ក្តីដាន់សាលាឧទ្ធរណ៍ឧទ្ធរណ៍ចំនួន ១៣.០០០រៀល គឺពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹង ២.៥៥០រៀល រង្វាន់ក្រឡាបញ្ជី ៤៥០រៀល ចំណាយលើការប្រគល់ដីកាកោះ ៥.០០០រៀលនិងអាជ្ញាធរតុលាការ ៥.០០០រៀល បូកសរុប ១៣.០០០រៀល និងអោយឈ្មោះ ឈីន នី បង់ពន្ធសមាមាត្រ មួយភាគរយលើប្រាក់ជំពាក់ ។

៥- សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណះចំពោះមុខគូក្តីបើកផ្លូវប្តឹងសាទុក្ខតាមកំណត់ច្បាប់។

បានឃើញបណ្តឹងសាទុក្ខលេខ ៤៤៨ ចុះថ្ងៃទី ២៤.១១.៩៧ របស់លោក ឈនបានប្តឹងមិនសុខចិត្តនិងសេចក្តីសំរេចនៃសាលដីកាលេខ ៧០១ចុះថ្ងៃទី ២៤.១១.៩៧របស់សាលាឧទ្ធរណ៍លើចំនុចនៃសាលដីកាទាំងមូល។

បានឃើញសារណាចុះថ្ងៃទី ២៥.០១.៩៩ របស់អ្នកស្រីឈន ។

បានឃើញសារណាតប ចុះថ្ងៃទី ១១.០៣.៩៩ របស់អ្នកស្រី អម ។

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា ៖ ក្រោយពីបានពិនិត្យលើសាលដីកាលេខ ៧០១ ចុះថ្ងៃទី ២៤.១១.៩៧របស់សាលាឧទ្ធរណ៍ការរកស៊ីហ៊ុនជាមួយគ្នាការអោយជួយលក់ផ្ទះ ឫ ដីធ្លីក្នុងបំណងយកកំរៃ គេពុំដែលយកប្លង់ទៅដាក់អោយម្ចាស់ផ្ទះទេ ។ ក្នុងករណីខាងលើនេះ ពិតជាមានការខ្ជីចងការពិតមែន ។ អាស្រ័យហេតុនេះ សូមក្រុមប្រឹក្សាជំនុំជំរះ មេត្តាពិចារណាតាមច្បាប់តទៅ ។

ក្រឡាបញ្ជីឡើងអានសារណារបស់ឈ្មោះ ឈន ។

ក្រឡាបញ្ជីឡើងអានសារណាតបរបស់ឈ្មោះ អម ។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីស្តាប់សារណារបស់គូភាគី
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

តុលាការកំពូល

- យល់ឃើញថាបណ្តឹសាទុក្ខលេខ ៤៤៨ ចុះថ្ងៃទី ២៤.១១.៩៧ របស់អ្នកស្រី ឈន ស្ថិតក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ។
- យល់ឃើញថាការដែលសាលាឧទ្ធរណ៍សំរេចអោយឈ្មោះ ឈន ប្រគល់ប័ណ្ណសំគាល់សិទ្ធិដី និង ផ្ទះអោយទៅឈ្មោះ អម វិញ និង អោយឈ្មោះ អម រួចផុតពីកាតព្វកិច្ចដោយយល់ថាមាត្រា ៤-៥ នៃក្រឹត្យ-ច្បាប់លេខ ៣៨ក្រ.ច ចុះថ្ងៃទី ២៨.១០.៨៨កំណត់ថា កិច្ចសន្យាទាំងឡាយណាដែលមានទឹកប្រាក់លើសពី ៥.០០០រៀលឡើងទៅត្រូវធ្វើជាលាយលក្ខអក្សរ ពុំនោះទេត្រូវទុកជាមោឃៈនោះជាការពិតមែនហើយ ប៉ុន្តែក្នុងករណីនេះការដែល អម យកប្លង់ដីលំនៅដ្ឋានដាកធានាជាមួយឈ្មោះ ឈន ដើម្បីបានប្រាក់នោះបញ្ជាក់ពីទំនាក់ទំនងខ្ចីចងការ ឫដាក់បញ្ចាំហើយ ហើយការអះអាងថាឈ្មោះ អម

យកប្រាក់ទៅចូលហ៊ុនរកស៊ីជាមួយឈ្មោះ ឈន នោះក៏ពុំមានឯកសារ ឫភស្តុតាងណាបញ្ជាក់ដែលអាចអោយជឿបានឡើយ ។

- យល់ឃើញថាការអះអាងរបស់ឈ្មោះ អម ថាខ្លួនបានយកប្លង់ដីលំនៅដ្ឋាននិងកូនលោរផ្ទះទៅអោយឈ្មោះ ឈន ដើម្បីជួយលក់ផ្ទះ ហើយអោយកំរៃនោះ ក៏ជាការពុំត្រឹមត្រូវដែរ ពីព្រោះជាទម្លាប់ទូទៅគេពុំដែលយកប្លង់អចលនៈទ្រព្យរបស់ខ្លួនទៅដាក់អោយជនណាម្នាក់ ដើម្បីអោយជួយលក់ទ្រព្យដោយពុំមានការធានានោះទេ ។
- យល់ឃើញថាគូភាគីបានធ្វើសារណាការពាររឿងក្តីរបស់ខ្លួនជូនមកតុលាការកំពូលរួចហើយ ប៉ុន្តែពុំបានមករួមសវនាការនេះទេ ដូច្នេះតុលាការកំពូលជំនុំជំរះរឿងនេះកំបាំងមុខគូភាគី ប៉ុន្តែចាត់ទុកជាចំពោះមុខ ។
- យល់ឃើញថាសាលដីការដ្ឋប្បវេណីលេខ ៧០១ ចុះថ្ងៃទី ២៤.១១.៩៧ របស់សាលាឧទ្ធរណ៍ដែលសំរេចសេចក្តីមកនេះមានការខុសឆ្គងទាំងទំរង់ ទាំងគតិច្បាប់ ។

ហេតុដូច្នេះ

វិនិច្ឆ័យសេចក្តីចំពោះមុខគូក្តី ប៉ុន្តែចាត់ទុកជាចំពោះមុខ

១- ទទួលបណ្តឹងសាទុក្ខលេខ ៤៤៨ចុះថ្ងៃទី ២៤.១១.៩៧របស់អ្នកស្រី ឈន ទុកជាត្រឹមត្រូវតាមទំរង់និងគតិច្បាប់ ។

២- ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ ៧០១ ចុះថ្ងៃទី ២៤.១១.៩៧របស់តុលាការកំពូលទៅសាលាឧទ្ធរណ៍ទាំងមូល ។

៣- បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ ០៥ ចុះថ្ងៃទី ០៨.០១.៩៨ របស់តុលាការកំពូលទៅសាលាឧទ្ធរណ៍ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

៤- រឹបអូសប្រាក់ប្រដាប់ក្តីដែលអ្នកស្រី ឈន បានបង់ទុកនៅតុលាការកំពូលចំនួន ១៩.០០០រៀល គឺៈ

- ពន្ធចុះបញ្ជីក្តី និង ពន្ធហ្នឹងចំនួន ៤.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន ៨០០រៀល សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហឹបប្រាក់
- ចំណាយក្នុងការប្រគល់ដីកាកោះចំនួន ១៥.០០០រៀល សរុប ១៩.០០០រៀល ហើយតំរូវអោយចុងចម្លើយសងប្រាក់ចំនួន ១៩.០០០រៀលនេះទៅដើមចោទវិញ ។

៥- សាលដីកានេះប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ១៩៩៩ ។